# សេចក្តីថ្លែងការណ៍

# របស់គណៈប្រតិភូវាយតម្លៃស្ថានភាពមុនការបោះឆ្នោត

# នៃវិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) នៅកម្ពុជា

## ភ្នំពេញ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៨

សេចក្តីថ្លែងការណ៍នេះ បានធ្វើឡើងដោយគណៈប្រតិភូអន្តរជាតិ និងរៀបចំដោយវិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ (NDI) ដែលបានអញ្ជើញមកធ្វើទស្សនៈកិច្ចនៅទីក្រុងភ្នំពេញកាលពីថ្ងៃទី៣១ ខែមីនា ដល់ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៨។ គណៈប្រតិភូបានពិនិត្យឡើងវិញនូវបរិយាកាសនយោបាយ ការរៀបចំការបោះឆ្នោត និងក្របខ័ណ្ឌច្បាប់សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ខាងមុខនេះ។

គណៈប្រតិភូទាំងអស់រួមមាន លោកស្រី ណូរ៉ា អូវ៉ែន (Nora Owen) អតីតរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ប្រទេសអៀរឡង់ លោក សេម ហ្គេជឌិនសុន (Sam Gejdenson) អតីតសមាជិកសភាអាមេរិក និងជាសមាជិកអ្នកប្រជាធិបតេយ្យនៃគណៈកម្មាធិការទំនាក់ទំនងអន្តរជាតិ លោក ម៉ាក ប្រាឌិន (Mark Braden) អតីតអគ្គមេធាវីនៃគណៈកម្មាធិការជាតិសាធារណៈរដ្ឋ (Republican National Committee) និងជាអ្នកជំនាញការច្បាប់បោះឆ្នោត លោកបណ្ឌិត ធូដុង មូលយ៉ា លូប៊ីស (Todung Mulya Lubis) មកពីប្រទេសឥណ្ឌូនេស៊ី ជាមេធាវីដ៏ល្បីល្បាញ និងជាប្រធាននៃអង្គការតម្លាភាពអន្តរជាតិប្រទេសឥណ្ឌូនេស៊ី (Transparency International-Indonesia) ព្រមទាំង លោក ភីធើ ម៉ានីកាស (Peter Manikas) មកពីសហរដ្ឋអាមេរិក ជានាយកនៃកម្មវិធីប្រចាំអាស៊ីរបស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) ។ សមាជិកគណៈប្រតិភូ ក៏ទទួលបានការជួយសម្រួលដោយបុគ្គលិកវិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) ដោយរួមមាន លោក ជេរ៉ូម ជឿង (Jerome Cheung) ប្រធានទីប្រឹក្សាបច្ចេកទេស និងជានាយកប្រចាំប្រទេសរបស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) ព្រមទាំង កញ្ញា ជូម៉ាណា ដាឡាល (Jumana Dalal) លោក តារីកុល ហ្គានី (Tarikul Ghani) លោក ប៊ឹង សំអឿន (Poeung Sam Oeurn) និងលោក លី សុធារ៉ាយុត្ត (Lee Sothearayuth)។

គណៈប្រតិភូ បានព្យាយាម ដើម្បីសម្តែងនូវការចាប់អារម្មណ៍ និងកង្វល់របស់សហគមន៍អន្តរជាតិទៅលើការរីកចំរើនរបស់ប្រទេសកម្ពុជាចំពោះការអភិវឌ្ឍស្ថាប័នប្រជាធិបតេយ្យ។ គណៈប្រតិភូ បានជួបប្រជុំជាមួយនឹងមន្ត្រីបោះឆ្នោត និងមន្ត្រីរដ្ឋាភិបាល មេដឹកនាំគណបក្សនយោបាយ មន្ត្រីសង្គមស៊ីវិល និងសិទ្ធិមនុស្ស ព្រមទាំងតំណាងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងសហគមន៍អន្តរជាតិ។ គណៈប្រតិភូ បានធ្វើការសង្កត់ធ្ងន់ថាខ្លួនមិនបានស្វះស្វែងដើម្បីសំរេចនូវសេចក្តីសន្និដ្ឋានចុងក្រោយណាមួយ លើដំណើរការបោះឆ្នោតឆ្នាំ២០០៨នៅឡើយទេ។ គណៈប្រតិភូ បានផ្តល់នូវរបាយការណ៍ និងអនុសាសន៍របស់ខ្លួនមួយចំនួនដោយឈរលើស្មារតីសហប្រតិបត្តិការ

អន្តរជាតិ និងទទួលស្គាល់ថាមានតែប្រជាជនកម្ពុជាទេ គឺជាអ្នកកំណត់នូវភាពគួរឱ្យជឿជាក់ទៅលើការបោះឆ្នោតនាពេលខាងមុខនេះ ។

**បរិយាកាសនយោបាយ**

គិតចាប់តាំងពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅឆ្នាំ១៩៩១មកប្រទេសកម្ពុជាកំពុងតែធ្វើដំណើរទៅរកការបោះឆ្នោតជាតិជាលើកទីបួន ។ ថ្វីត្បិតតែការបោះឆ្នោតមុនៗ ធ្លាប់មានគុណវិបត្តិយ៉ាងធ្ងន់ធ្ងរក៏ដោយក៏ការរីកចម្រើនបានកើតមានឡើង នៅពេលដែលប្រជាជនកម្ពុជាបានសម្រេចចិត្តទៅបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅឆ្នាំ២០០៣ ។ អំពើហឹង្សាក្នុងឆាកនយោបាយមានការថយចុះ ហើយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ត្រូវបានរៀបចំឡើងវិញ និងបានប្រតិបត្តការងាររបស់ខ្លួនកាន់តែមានតម្លាភាពជាងមុន មិនតែប៉ុណ្ណោះ ក៏មានការកើនឡើងនូវចំនួននៃការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យនយោបាយផងដែរ រីឯគណបក្សប្រឆាំងក៏មានចំនួនកើនឡើងផងដែរបើទោះបីជាលទ្ធភាពទទួលបានប្រព័ន្ធសម្រាប់ផ្សព្វផ្សាយនៅមានកម្រិតក៏ដោយ ។

ទោះជាយ៉ាងណាក៏ដោយ ក៏បញ្ហាសំខាន់ៗនៅតែកើតមាននៅក្នុងដំណើរការបោះឆ្នោតនៅប្រទេសកម្ពុជា ។ បញ្ហាសំខាន់ៗទាំងនេះ ត្រូវបានគេកត់សម្គាល់ថា មានការជាប់ទាក់ទងនឹងការបោះឆ្នោតកន្លងមក ។ គណបក្សប្រជាជនកម្ពុជា បានគ្រប់ដណ្តប់លើទិដ្ឋភាពនយោបាយតាំងពីការបោះឆ្នោតឧបត្ថម្ភដោយអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៣មកម្ល៉េះ (ដោយពីមុនជា គណបក្សបដិវត្តន៍ប្រជាជនកម្ពុជា (Kampuchean People's Revolutionary Party- KPRP) ដែលដឹកនាំនៅក្នុងឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៩១) ។ មរតករបស់រដ្ឋដែលមានគណបក្សតែមួយ និងការបន្តការគ្រប់គ្រងរបស់គណបក្សប្រជាជនកម្ពុជា លើប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិច យោធា ប៉ូលីស តុលាការ ការិយាធិបតេយ្យស៊ីវិល និងមន្ត្រីមូលដ្ឋាន បានធ្វើឱ្យពិបាកក្នុងការញែកឱ្យដាច់រវាងគណបក្ស និងរដ្ឋាភិបាល ។ ព្រឹត្តិការណ៍ផ្សេងៗទៀតដូចជា រដ្ឋប្រហារនៅឆ្នាំ១៩៩៧ដែលគណបក្សប្រជាជនកម្ពុជាបានផ្តួលរំលំដៃគូនយោបាយដោយអំពើហឹង្សា បានបង្កឱ្យមានការមិនទុកចិត្តគ្នាយ៉ាងខ្លាំងរវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំង ។

គណៈប្រតិភូ ជឿជាក់ថាដោយសារតែគណបក្សប្រជាជនកម្ពុជា គ្រប់គ្រងអំណាចនយោបាយតែឯង និងមានការមិនទុកចិត្តគ្នា ដែលបានជ្រាបចូលយ៉ាងជ្រៅនៅក្នុងបរិយាកាសនយោបាយ រដ្ឋាភិបាលមានកាតព្វកិច្ចពិសេសដើម្បីធានាអះអាងថា ការបោះឆ្នោតខាងមុខនេះ គឺជាការបោះឆ្នោតប្រកបដោយយុត្តិធម៌សម្រាប់គ្រប់គណបក្សប្រកួតប្រជែងទាំងអស់ ។

ខណៈពេលដែលការសំលាប់ទាក់ទងនឹងនយោបាយបានកាត់បន្ថយ និងមានការអធ្យាស្រ័យដ៏លើសលប់ដល់សកម្មភាពនយោបាយរបស់គណបក្សប្រឆាំងទូទាំងប្រទេស មន្ត្រីរដ្ឋាភិបាលខេត្ត និងមូលដ្ឋានបានបន្តការកាត់បន្ថយសកម្មភាពស្របច្បាប់របស់អង្គការមិនមែនរដ្ឋាភិបាល និងសកម្មជនគណបក្សប្រឆាំង ។ លើសពីនេះទៅទៀត រដ្ឋាភិបាលបានប្រើប្រាស់នីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌម្តងហើយម្តងទៀត ដើម្បីប្រឆាំងនឹងសមាជិកគណបក្សប្រឆាំង

និងអ្នករិះគន់រដ្ឋាភិបាលដទៃទៀត។ ចាប់តាំងពីការបោះឆ្នោតឆ្នាំ២០០៣មក មេដឹកនាំគណបក្សប្រឆាំងធំៗពីរគឺ លោក សម រង្ស៊ី (ប្រធានគណបក្សសម រង្ស៊ី) និងសម្ដេចក្រុមព្រះនរោត្ដមរណឫទ្ធិ (ប្រធានគណបក្សនរោត្ដមរណឫទ្ធិ) ត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងបាននិរទេសខ្លួនចេញពីប្រទេស។ បច្ចុប្បន្ននេះ លោក សម រង្ស៊ី មានវត្តមាននៅក្នុងប្រទេស ហើយគណបក្សសម រង្ស៊ី មានគម្រោងចូលរួមនៅក្នុងការបោះឆ្នោតខាងមុខនេះ។ តែសម្ដេចក្រុមព្រះនរោត្ដមរណឫទ្ធិ នៅតែឋិតនៅក្នុងភាពនិរទេសខ្លួនដដែលទោះបីជាគណបក្សនរោត្ដមរណឫទ្ធិមានបំណងដាក់បេក្ខជននៅក្នុងការបោះឆ្នោតខាងមុខនេះដែរក៏ដោយ។ កាលពីខែមុនសកម្មជនគណបក្សសម រង្ស៊ីបីនាក់ ត្រូវបានចាប់ខ្លួន ហើយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចោទប្រកាន់ជាសាធារណៈទៅលើលោកជំទាវ ជូឡុង សូមូរ៉ា ដែលជាសមាជិកសភានៃគណបក្ស សម រង្ស៊ី ពីបទចាប់ពង្រត់អតីតមន្ត្រីគណបក្ស សម រង្ស៊ីម្នាក់ដើម្បីរារាំងមិនឱ្យចុះចូលជាមួយគណបក្សប្រជាជនកម្ពុជា។

រដ្ឋាភិបាល បានប្រើច្បាប់បរិហារកេរ្តិ៍ដើម្បីរឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិ។ នៅចុងឆ្នាំ ២០០៥ និងដើមឆ្នាំ២០០៦ មានអ្នកសារព័ត៌មាន និងមេដឹកនាំសង្គមស៊ីវិល៥នាក់ ដោយក្នុងនោះរួមមាន លោក ម៉ម សុណង់ដូ ម្ចាស់ស្ថានីយ៍វិទ្យុសំបុកឃ្មុំ និងលោក កឹម សុខា ប្រធានអង្គការសិទ្ធិមនុស្ស សុទ្ធតែត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍។ ការចោទប្រកាន់នោះទាក់ទងទៅនឹងការរិះគន់រដ្ឋាភិបាល អំពីបញ្ហាព្រំដែនកម្ពុជា-វៀតណាម។ ដោយសារតែគ្មានប្រព័ន្ធតុលាការឯករាជ្យ និងមិនមានប្រសិទ្ធិភាព ការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌត្រូវបានប្រើប្រាស់ដើម្បីប្រឆាំងនឹងអ្នកប្រឆាំងរដ្ឋាភិបាលនោះ វាហាក់ដូចជាមិនស្របតាមចំណាត់ការច្បាប់ដ៏សមរម្យឡើយ។ ការកាត់ទោសបែបនេះ ឆ្លុះបញ្ចាំងអោយឃើញនូវការចោទប្រកាន់ដែលមានហេតុផលនយោបាយ យ៉ាងពេញទំហឹង ហើយបានប្រើប្រាស់វាដើម្បីបង្ក្រាបគូប្រឆាំង។ លទ្ធផលបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ នៅខែមេសា ឆ្នាំ២០០៧ បង្ហាញថា ប្រព័ន្ធនយោបាយនៅកម្ពុជាកាន់តែមានលក្ខណៈប្រកួតប្រជែងជាងមុន។ ឧទាហរណ៍ ទោះបីជាគណបក្សប្រជាជនកម្ពុជា នៅតែគ្រប់គ្រងភាគច្រើនបំផុតនៃក្រុមប្រឹក្សាឃុំ-សង្កាត់ចំនួន១៦២១ទូទាំងប្រទេសក៏ដោយ ក៏គណបក្សប្រឆាំងបានកើនចំនួនអសនៈ នៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ទ្វេដងហើយមានតំណាងរបស់ខ្លួនជាង៩០ភាគរយនៃក្រុមប្រឹក្សាឃុំ-សង្កាត់។ ទោះជាយ៉ាងណាក្ដី ទង្វើថ្មីៗរបស់រដ្ឋាភិបាលដែលរារាំងសេរីភាពនៃការបញ្ចេញមតិ និងសេរីភាពនៃការប្រជុំ បានធ្វើឱ្យប្រជាជនកាន់តែមានកង្វល់ថែមទៀតចំពោះការសន្យាថាធ្វើឱ្យមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដមួយ ដែលនេះនឹងកើតមានឡើងនៅក្នុងអនាគតកាលដ៏យូរអង្វែង។ រដ្ឋាភិបាល និងគណបក្សកាន់អំណាច អាចនឹងមានមោទនភាពចំពោះសមិទ្ធិផលរបស់ខ្លួន ដូចជាការកសាងផ្លូវថ្នល់ សាលារៀន និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ ប្រជាជនកម្ពុជា អាចសាទរនឹងគណបក្សប្រជាជនកម្ពុជា ចំពោះការបំពេញតួនាទីក្នុងការសម្រេចបាននូវស្នាដៃអស់ទាំងនេះ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ឆន្ទៈរបស់ប្រជាជនកម្ពុជា មិនអាចត្រូវបានគេដឹងច្បាស់បានឡើយលុះត្រាតែប្រជាជនកម្ពុជា អាចចូលរួមនៅក្នុងដំណើរការនយោបាយដែលមានយុត្តិធម៌ដល់គ្រប់បេក្ខជន និងគណបក្សនយោបាយទាំងអស់។

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ( គ.ជ.ប)**

ចាប់តាំងពីការបោះឆ្នោតជាតិនៅឆ្នាំ២០០៣មក ការផ្លាស់ប្តូរច្បាប់បោះឆ្នោត និងបទបញ្ជា-នីតិវិធីរបស់ គ.ជ.បមួយចំនួន បានធ្វើឱ្យ**គ.ជ.ប**កាន់តែមានតម្លាភាពជាងមុន។ សមាជិករបស់ **គ.ជ.ប** បានពង្រីក ចំនួនពី៥នាក់ ទៅ៩នាក់។ គណបក្សប្រឆាំង អាចតែងតាំងមនុស្សរបស់ខ្លួនជាសមាជិក **គ.ជ.ប**បាន ទោះបីជាគ្រប់សមាជិករបស់ **គ.ជ.ប**ទាំងអស់ ត្រូវតែលះបង់ការជាប់ទាក់ទងនឹងគណបក្សណាមួយ ហើយត្រូវធ្វើការដោយអព្យាក្រិត និង មិនលំអៀងទៅរកគណបក្សណាមួយក៏ដោយ។ គណបក្ស សម រង្ស៊ី បានតែងតាំងសមាជិករបស់ខ្លួនចំនួន២នាក់ ជាសមាជិករបស់ **គ.ជ.ប** បច្ចុប្បន្ន។

**គ.ជ.ប** ក៏បានអោយតំណាងពីសង្គមស៊ីវិល និងគណបក្សនយោបាយចូលរួមនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និង ថ្នាក់ឃុំផងដែរ។ ចំពោះការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០០៧ **គ.ជ.ប** បានបញ្ចូលតំណាងសង្គមស៊ីវិល និង គណបក្សនយោបាយនានា ឱ្យចូលរួមនៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួន ដើម្បីពង្រីកការយល់ដឹងលើនីតិវិធី ច្បាប់បោះឆ្នោត និងដំណើរការប្តឹង។ ជាថ្មីម្តងទៀត **គ.ជ.ប** ក៏មានបំណងផលិតសៀវភៅស្តីពីព័តិមាន និង ការបណ្តុះបណ្តាលដែលសង្គមស៊ីវិល និងគណបក្សនយោបាយអាចប្រើប្រាស់បានផងដែរ។

ឆ្លើយតបទៅនឹងការចោទប្រកាន់ពីភាពលំអៀង នៅក្នុងការជ្រើសរើសបុគ្គលិកបោះឆ្នោតនៅក្នុងឆ្នាំ២០០៧ **គ.ជ.ប** បានលុបចោលនូវតម្រូវការរបស់ខ្លួនថា គ្រប់បុគ្គលិកបោះឆ្នោត ត្រូវមានបទពិសោធន៍ខាងធ្វើការបោះឆ្នោត កន្លងមក។ ហើយ គ.ជ.ប ក៏បានកាត់បន្ថយអប្បបរិមាអាយុពី២២ឆ្នាំទៅ១៨ឆ្នាំវិញ។ ការធ្វើយ៉ាងនេះបានពង្រីក នូវទំហំអ្នកធ្វើការងារបោះឆ្នោតប្រកបដោយសក្តានុពល។ នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ-សង្កាត់ឆ្នាំមុន បុគ្គលិកបោះឆ្នោតដែលបានជ្រើសរើសជិត៣០ភាគរយសុទ្ធតែជាស្ត្រី ហើយ**គ.ជ.ប**ក៏បានព្យាយាម ជ្រើសរើសជនជាតិភាគតិចនៅតាមបណ្តារខេត្តមួយចំនួនផងដែរ។

**គ.ជ.ប** បានផ្តួចផ្តើមជំហានមួយចំនួន ដើម្បីទាក់ទងយ៉ាងទៀងទាត់ជាមួយនឹងគណបក្សនយោបាយ និង សង្គមស៊ីវិលនានា។ ដំណាក់កាលទាំងនេះ រួមមានការប្រជុំប្រចាំសប្តាហ៍នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត និងការប្រជុំ ប្រចាំខែ ដែលសហការឧបត្ថម្ភដោយកម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ (UNDP) នៅទីក្រុងភ្នំពេញ។ នាពេល ដែលការប្រជុំ UNDP ត្រូវបានគេគិតថាមានប្រយោជន៍យ៉ាងខ្លាំង ការប្រជុំប្រចាំសប្តាហ៍នៅតែមិនអាចកសាង នូវទំនុកចិត្តរវាងអង្គការសង្គមស៊ីវិល គណបក្សនយោបាយ និងគ.ជ.ប រហូតនោះទេ។ តំណាងអង្គការ សង្គមស៊ីវិល និងគណបក្សប្រឆាំងខ្លះយល់ឃើញថា ការប្រជុំប្រចាំសប្តាហ៍ ជាការរៀបចំឡើងសម្រាប់ជាយានដើម្បីឱ្យគ.ជ.ប ផ្សព្វផ្សាយព័តិមានជាជាងប្រើប្រាស់ជាយន្តការសម្រាប់ដោះស្រាយបញ្ហាដែលកើតមាន។ ជាលទ្ធផលការប្រជុំ ប្រចាំសប្តាហ៍ អាចនឹងមានផលវិបាកដែលនាំឱ្យមានការមិនទុកចិត្តគ្នាកាន់តែខ្លាំងឡើងរវាង តួអង្គដែលពាក់ព័ន្ធ នៅក្នុងដំណើរការបោះឆ្នោត។

បញ្ជីឈ្មោះអ្នកបោះឆ្នោតដ៏ត្រឹមត្រូវជួយធានាថា មានតែអ្នកមានសិទ្ធិបោះឆ្នោតប៉ុណ្ណោះដែលអាចបោះឆ្នោត នៅថ្ងៃបោះឆ្នោតបាន និងជួយរារាំងនូវការក្លែងបន្លំសន្លឹកឆ្នោត។ នៅក្នុងការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នក

បោះឆ្នោតថ្មីសម្រាប់ការបោះឆ្នោតជាតិ ឈ្មោះអ្នកបោះឆ្នោតចំនួន៥៨៧១៦០ ត្រូវបានលុបចេញពីបញ្ជីតាំងពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ខែមេសា ឆ្នាំ២០០៧មក។ មានបុគ្គលជាច្រើនបាននិយាយថា ចំនួនអ្នកមានសិទ្ធិបោះឆ្នោតជាច្រើនគួរឱ្យកត់សម្គាល់ ប្រហែលជាត្រូវបានគេលុបចេញមិនបានត្រឹមត្រូវនៅក្នុងដំណើរការលុបឈ្មោះនេះទេ។ ជាមួយគ្នានេះដែរ គណបក្សប្រឆាំងបានលើកឡើងពីកង្វល់ថាដោយសារតែបញ្ជីលុបឈ្មោះអ្នកបោះឆ្នោតនេះ ត្រូវបានរៀបចំដោយមន្ត្រីភូមិ និងឃុំដែលជាអ្នកគាំទ្រគណបក្សប្រជាជនដ៏លើសលុប ពួកគេអាចនឹងមានភាពលំអៀងខាងផ្នែកនយោបាយ នៅក្នុងការលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោតនេះ។ ដំណើរការដែលប្រើសម្រាប់រៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតក៏ប្រហែលជាមានការរើសអើងដោយអចេតនាផងដែរ ចំពោះអ្នកចំណាកស្រុកដែលមិនមានវត្តមាននៅក្នុងភូមិស្រុករបស់ពួកគេ ដើម្បីពិនិត្យមើលឈ្មោះនៅក្នុងបញ្ជីលុបឈ្មោះនោះ។ លើសពីនេះទៅទៀត មានអ្នកភូមិជាច្រើន មិនសូវដឹងពីព័ត៌មានទាក់ទងនឹងដំណើរការចុះឈ្មោះ និងលុបឈ្មោះអ្នកបោះឆ្នោតនេះផ្ទាល់តែម្តង។ គណបក្សនយោបាយមួយចំនួន បានប្រមូលផ្តុំអ្នកគាំទ្រឱ្យពិនិត្យមើលបញ្ជីឈ្មោះអ្នកបោះឆ្នោត ក៏ប៉ុន្តែគណបក្សភាគច្រើន ខ្វះសមត្ថភាពដើម្បីទទួលកិច្ចការបែបនេះនៅថ្នាក់ជាតិ។ គណៈប្រតិភូជឿជាក់យ៉ាងមុតមាំថា កិច្ចប្រឹងប្រែងរួបរួមគ្នាត្រូវតែធ្វើឡើងដើម្បីជួយធានាថា អ្នកមានសិទ្ធិបោះឆ្នោត មិនត្រូវបានគេរារាំងពីការទៅបោះឆ្នោតនៅថ្ងៃបោះឆ្នោត ដោយសារតែបញ្ជីឈ្មោះអ្នកបោះឆ្នោតមានការខុសឆ្គងនេះឡើយ។

ថ្វីត្បិតតែកំណែទម្រង់របស់ គ.ជ.ប បានធ្វើឱ្យមានការរីកចំរើនលើការគ្រប់គ្រង ការបោះឆ្នោតនៅក្នុងប្រទេសកម្ពុជាគួរឱ្យកត់សម្គាល់យ៉ាងណាក៏ដោយ ក៏បញ្ហាចម្បង១មួយចំនួននៅតែកើតមានដែរ ពោលគឺកង្វល់អំពីឯករាជ្យភាពរបស់គ.ជ.ប។ ទស្សនៈអំពីសេចក្តីលំអៀងមួយផ្នែក គឺដោយសារតែទីតាំងរបស់ គ.ជ.ប បច្ចុប្បន្ននេះនៅក្នុងក្រសួងមហាផ្ទៃ។ មិនតែប៉ុណ្ណោះ គ.ជ.ប ពុំមានអណត្តិឯករាជ្យតាមផ្លូវច្បាប់ឡើយ ចំណែកឯថវិការបស់ខ្លួនវិញក៏ត្រូវគ្រប់គ្រងដោយក្រសួងមហាផ្ទៃ ដែលវាកាន់តែគាំទ្រនូវទស្សនៈថាការគ្រប់គ្រងការបោះឆ្នោតមានលក្ខណៈលំអៀង។

**ប្រព័ន្ធផ្សព្វផ្សាយ**

លទ្ធភាពដែលអាចទទួលបានប្រព័ន្ធផ្សព្វផ្សាយស្មើ១គ្នា ដោយបេក្ខជន និងគណបក្សប្រកួតប្រជែងនានាមានសារៈសំខាន់សម្រាប់ភាពត្រឹមត្រូវនៃការបោះឆ្នោត។ រាល់អ្នកប្រកួតប្រជែងខាងផ្នែកនយោបាយទាំងអស់ត្រូវតែមានលទ្ធភាពជួបអ្នកបោះឆ្នោត ដើម្បីផ្តល់នូវសារ និងអំពាវនាវរកការគាំទ្រពីអ្នកបោះឆ្នោត។ ជាអកុសលលទ្ធភាពអាចទទួលបានប្រព័ន្ធផ្សព្វផ្សាយតាមអេឡិចត្រូនិច របស់គណបក្សប្រឆាំងដែលត្រូវកំរិតនោះ គឺជាឧបសគ្គមួយដ៏ចម្បងចំពោះការរៀបចំការបោះឆ្នោតដែលអាចជឿទុកចិត្តបាន។

គ្រប់គណបក្សនយោបាយធំ១ទាំងអស់ មានលទ្ធភាពទទួលបាននូវការបោះពុម្ពផ្សាយតួយ៉ាងដូចជាកាសែតគឺជាប្រភពព័ត៌មានផ្សេង១គ្នា និងមានឥទ្ធិពលនៅក្នុងប្រទេសកម្ពុជា។ សារព័ត៌មានជាភាសាខ្មែរមួយភាគធំ

ពាក់ព័ន្ធនឹងគណបក្សនយោបាយ រួមទាំងគណបក្សប្រឆាំង និងការរិះគន់រដ្ឋាភិបាលជាញឹកញាប់។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏សារព័ត៌មាន (កាសែត) បានទៅដល់ប្រជាជនខ្មែរតិចតួចណាស់។

យោធា រដ្ឋាភិបាល និងគណបក្សកាន់អំណាច មានឥទ្ធិពលលើប្រព័ន្ធផ្សព្វផ្សាយ។ ឥទ្ធិពលរបស់គេបន្តការរិតត្បិតលទ្ធភាពរបស់គណបក្សប្រឆាំង និងការរិះគន់របស់សង្គមស៊ីវិលមិនអោយទៅដល់ប្រជាជនកម្ពុជាភាគច្រើន។

ប្រព័ន្ធផ្សព្វផ្សាយ ក៏មានការរីកលូតលាស់ផងដែរនៅប៉ុន្មានឆ្នាំថ្មីៗនេះ គឺមានដល់ទៅជាង៣០ស្ថានីយ៍វិទ្យុ។ ភាគច្រើន គឺផ្តល់នូវកម្មវិធីកំសាន្តអារម្មណ៍។ ស្ថានីយ៍វិទ្យុសំបុកឃ្មុំ (FM១០៥) ផ្តល់នូវលទ្ធភាពឱ្យមានសម្លេងរិះគន់រដ្ឋាភិបាលដ៏ច្រើនបំផុត និងមានគណបក្សប្រឆាំងបីគឺ គណបក្សសម រង្ស៊ី គណបក្សនរោត្តម រណឫទ្ធិ និងគណបក្សសិទ្ធិមនុស្សដែលបានទិញម៉ោងសំរាប់ការផ្សាយកម្មវិធីរបស់ខ្លួន។ មានស្ថានីយ៍មួយទៀត គឺ FM ៩៣.៥ នៅខេត្តបាត់ដំបង បានរួបរួមគ្នាជាមួយនឹងគណបក្សសម រង្ស៊ី។ ក្រៅពីនេះ FM ៩០ (ដែលមានការចាក់ផ្សាយបន្តផ្ទាល់នៅFM៩០.២៥ នៅក្នុងខេត្តបាត់ដំបងផងដែរ) គាំទ្រគណបក្សហ៊្វុនស៊ិនប៉ិច ដែលជាដៃគូរដ្ឋាភិបាល។ FM ៩០ ក៏បានផ្តល់ការគ្របដណ្តប់មានកំរិត សំរាប់ការផ្សាយសម្លេងប្រឆាំងតាមរយៈកម្មវិធីដែលទិញម៉ោងពីវិទ្យុនេះផងដែរ។ វិទ្យុសម្លេងសហរដ្ឋអាមេរិក (VOA) និងវិទ្យុអាស៊ីសេរី (RFA) ក៏មានការចាក់ផ្សាយកម្មវិធីរបស់ពួកគេនៅស្ថានីយ៍វិទ្យុសំបុកឃ្មុំយ៉ាងទៀងទាត់។

ការផ្តល់អាជ្ញាប័ណ្ណសំរាប់វិទ្យុ បង្ហាញថាមានភាពលំអៀង។ សមាជិកគណបក្សប្រឆាំង មានបំណងជាច្រើនសារដើម្បីទទួលបានអាជ្ញាប័ណ្ណសំរាប់វិទ្យុ ប៉ុន្តែត្រូវបានគេច្រានចោល ដោយឡែកការស្នើសុំពីអ្នកគាំទ្រគណបក្សប្រជាជនកម្ពុជា បែរជាត្រូវបានគេទទួលយកទៅវិញ ដូចជានៅឆ្នាំមុនរដ្ឋាភិបាល បានផ្តល់អាជ្ញាប័ណ្ណមួយដល់មន្ត្រីរដ្ឋាភិបាលគណបក្សប្រជាជននៅទីក្រុងភ្នំពេញ បន្ទាប់ពីការបដិសេធសំណើស្រដៀងគ្នានេះ ដែលស្នើសុំដោយក្រុមប្រឆាំង និងអ្នកក្រុមគាំទ្រសិទ្ធិមនុស្សអស់រយៈពេល៤ឆ្នាំ។ លើសពីនេះទៀត អ្នកសារព័ត៌មានណាដែលរិះគន់រដ្ឋាភិបាល ត្រូវបានគេយាយីរំខាន និងគំរាមកំហែង។ មានអ្នកសារព័ត៌មានជាច្រើននាក់បានសារភាពថាពួកគេបានធ្វើការបន្ទោសខ្លួនឯងដោយសេចក្តីភ័យខ្លាចពីការសងសឹកវិញដោយរដ្ឋាភិបាល។

នៅពេលដែលប្រជាជនខ្មែរភាគច្រើន ពឹងផ្អែកលើវិទ្យុជាប្រភពព័ត៌មានដ៏ចម្បង ឯទូរទស្សន៍កាន់តែមានសារៈសំខាន់ខ្លាំងផងដែរ។ មានស្ថានីយ៍ទូរទស្សន៍ចំនួន៧ ឯកជនចំនួន៦ និងទូរទស្សន៍ជាតិកម្ពុជា (ទទក)១ ដែលកាន់កាប់ និងគ្រប់គ្រងដោយរដ្ឋាភិបាល។ គ្រប់ស្ថានីយ៍ទូរទស្សន៍ទាំងអស់ ត្រូវបានគ្រប់គ្រងដោយផ្ទាល់ឬដោយប្រយោលដោយរដ្ឋាភិបាល។ ទូរទស្សន៍ជាតិកម្ពុជា (ទទក) ដែលជាទូរទស្សន៍របស់រដ្ឋ គឺជាស្ថានីយ៍តែមួយគត់ដែលគ្របដណ្តប់ទូទាំងប្រទេស ហើយក្រុមអ្នកត្រួតពិនិត្យការផ្សាយ និងគណបក្សប្រឆាំង មានការត្អូញត្អែរជានិច្ចពីការមិនបានផ្តល់នូវលទ្ធភាព ឬការគ្របដណ្តប់ប្រកបដោយសមធម៌នេះ។

ការអភិវឌ្ឍន៍ជាវិជ្ជមានបានកើតឡើងជាមួយនឹងការមកដល់នៃកម្មវិធីសមធម៌ (Equity News) និងកម្មវិធី សមធម៌ប្រចាំសប្តាហ៍ (Equity Weekly) ដែលឧបត្ថម្ភដោយ UNDP។ កម្មវិធីទាំងពីរនេះត្រូវបាន

ផ្សព្វផ្សាយដោយទូរទស្សន៍ជាតិកម្ពុជា។ កម្មវិធីសមធម៌ប្រចាំសប្តាហ៍ (Equity Weekly) ធ្វើតាមទម្រង់ព័ត៌មានទស្សនាវដ្តី និងផ្សាយរយៈពេលមួយម៉ោងជារៀងរាល់សប្តាហ៍ដែលរួមមានទាំងការរិះគន់រដ្ឋាភិបាល។ នៅអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតខាងមុខនេះ ដែលនឹងចាប់ផ្តើមរយៈពេល៣០ថ្ងៃមុនពេលថ្ងៃបោះឆ្នោតកម្មវិធីសមធម៌នឹងផ្តល់រយៈពេល២០នាទីក្នុងមួយថ្ងៃ និងចែករំលែកពេលស្មើៗគ្នាទៅគ្រប់គណបក្សទាំងអស់។

**នីតិរដ្ឋ**

នៅពេលដែលរបបខ្មែរក្រហមប្រល័យពូជសាសន៍ ត្រូវបានបណ្តេញចេញពីប្រទេសនៅឆ្នាំ១៩៧៩មក មានតែ៦នាក់តែប៉ុណ្ណោះដែលបានទទួលការបណ្តុះបណ្តាលអំពីវិស័យច្បាប់ដែលសេសសល់នៅក្នុងប្រទេស។ ការងារនៃការបង្កើតប្រព័ន្ធច្បាប់ឡើងវិញដែលមានចៅក្រមប្រកបដោយសមត្ថភាព មេធាវីការពារក្តី ព្រះរាជអាជ្ញា បុគ្គលិករដ្ឋបាល និងមន្ត្រីពន្ធនាគារ គឺមានការរុញរា។ ទោះបីជាឥឡូវនេះ មានចៅក្រមប្រហែល៣៥០នាក់នៅក្នុងប្រទេសក៏ដោយ ប្រព័ន្ធច្បាប់នៅតែមានលក្ខណៈខ្វះខាត និងមិនអាចការពារសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋនៃប្រទេសនេះបានឡើយ។ តុលាការ ជាទូទៅត្រូវបានគេចាត់ទុកថាខ្វះនូវឯករាជ្យភាពពីអង្គនីតិប្រតិបត្តិដែលតែងតែជ្រៀតជ្រែកនៅក្នុងសេចក្តីសម្រេចរបស់តុលាការ។

អាជ្ញាធរជាតិ និងអាជ្ញាធរមូលដ្ឋាន ត្រូវបានគេរកឃើញថាជាញឹកញាប់ជ្រៀតជ្រែកដោយខុសទៅនឹងដំណើរការយុត្តាធិការ។ ដោយសារតែការបង្ខំឱ្យមានសមូហនីយកម្មនៅក្នុងសម័យខ្មែរក្រហម និងការបណ្តេញប្រជាពលរដ្ឋរាប់លាននាក់ចេញពីទីក្រុង ម្ចាស់កម្មសិទ្ធិដីធ្លីភាគច្រើន ខ្វះនូវឯកសារផ្លូវការបញ្ជាក់ពីកម្មសិទ្ធិ។ តម្លៃដីដែលចេះតែឡើងនៅទីក្រុង និងជនបទ បានក្លាយជាទិសដៅរបស់ពួកឈ្មួញ និងអ្នកមានអំណាចដោយពេលខ្លះមានការឃុបឃិតជាមួយនឹងអាជ្ញាធរមូលដ្ឋាន ដើម្បីបង្ខំអ្នកកាន់កាប់ដីធ្លីចេញពីដីដែលពួកគាត់កំពុងតែរស់នៅជាយូរមកហើយ។

ច្បាប់ភូមិបាលនៅឆ្នាំ២០០១ បានចែងថាអ្នកដែលបានកាន់កាប់អចលនវត្ថុអស់រយៈពេល៥ឆ្នាំ អ្នកនោះនឹងមានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុនោះ។ តុលាការ មានយុត្តាធិការលើដីធ្លីណាដែលបានចុះបញ្ជី ឬដីនៅកន្លែងណាដែលអ្នកកាន់កាប់មានប័ណ្ណកម្មសិទ្ធិ។ មានការមិនពេញចិត្តយ៉ាងច្រើនពីសំណាក់មហាជននូវរបៀបដែលតុលាការបានធ្វើការដោះស្រាយជំលោះទាំងនេះ និងការជ្រៀតជ្រែកផ្នែកនយោបាយក្នុងករណីដីធ្លីដែលជាញឹកញាប់ត្រូវគេចោទប្រកាន់ ។ អង្គការសិទ្ធិមនុស្សនៅកម្ពុជា ដូចជា អាដហុក (ADHOC) និងលីកាដូ (LICHADO) បានដាក់ពាក្យបណ្តឹងរាប់រយករណីសុទ្ធសឹងតែពាក់ព័ន្ធនឹងការរំលោភយកដីធ្លីនៅឆ្នាំមុន។ បញ្ហារំលោភយកដីធ្លីបាននាំអោយមានការតវ៉ាជាទ្រង់ទ្រាយធំ នៅតាមតំបន់មួយចំនួននៅក្នុងប្រទេស ដែលពេលខ្លះការតវ៉ានោះត្រូវបានប៉ូលីសបំបែកដោយអំពើហិង្សា។ អង្គការមិនមែនរដ្ឋាភិបាល ដែលបានដើរតួធ្វើជាអ្នកជួយតស៊ូមតិ និងតវ៉ាឱ្យអ្នកដែលដីធ្លីរបស់ពួកគេទាំងនោះ ត្រូវបានដកហូតត្រូវបានគេតាមយាយីរំខាន និងគម្រាមកំហែង។ ការរំលោភយកដីធ្លីបានក្លាយទៅជាបញ្ហានយោបាយដ៏សំខាន់មួយ នឹងអាចនាំទៅរកអំពើហិង្សាជាច្រើននៅពេលដែលការបោះឆ្នោតកំពុងខិតជិតមកដល់។

គណៈប្រតិភូបានកត់សំគាល់នូវឧទាហរណ៍ជាក់ស្តែងមួយចំនួនរបស់រដ្ឋាភិបាលដែលប្រើប្រាស់អំណាចរបស់ខ្លួនដោយលំអៀងក្នុងការអនុវត្តច្បាប់ ដូចជាការកាត់ទោសគូបដិបក្ខនយោបាយរបស់ខ្លួន ការផ្តល់នូវអាជ្ញាប័ណ្ណផ្សព្វផ្សាយដល់អ្នកគាំទ្រគណបក្សប្រជាជនកម្ពុជា និងការបដិសេធមិនផ្តល់អាជ្ញាបណ្ណ័ដល់ភាគីប្រឆាំង និងការប្តឹងពីបទបរិហារកេរ្តិ៍រដ្ឋប្បវេណី និងព្រហ្មទណ្ឌប្រឆាំងនឹងអ្នកសារព័ត៌មាន និងអ្នករិះគន់រដ្ឋាភិបាល។ រដ្ឋាភិបាលក៏បានរំលោភអំណាចរបស់ខ្លួនឯងដោយមិនអនុញ្ញាតអោយមានការប្រជុំមហាជន និងការតវ៉ាហើយជាញឹកញាប់ប៉ុនប៉ងហាមឃាត់ពួកគេដោយមិនសមហេតុផលដោយសំអាងលើហេតុផល "បាត់បង់សណ្តាប់ធ្នាប់សាធារណៈ" ។

ការខ្វះខាតដំណើរការច្បាប់ដ៏ត្រឹមត្រូវ និងមានសមត្ថភាពធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធបោះឆ្នោតដោយផ្ទាល់។ បើមិនមានដំណើរការច្បាប់មួយដែលអាចជឿបាននោះទេ បេក្ខជននិងគណបក្សប្រឆាំង មិនអាចពឹងផ្អែកលើតុលាការ និងអាជ្ញាធរអនុវត្តច្បាប់ ដើម្បីអនុវត្តសិទ្ធិរបស់ពួកគេនៅក្នុងវិស័យបោះឆ្នោតបានទេ។

**សង្គមស៊ីវិល និងការឃ្លាំមើលការបោះឆ្នោត**

ប្រទេសកម្ពុជា មានអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃចំនួនជាង២០០០ ដែលភាគច្រើនបានបង្កើតឡើងនៅរវាង ឆ្នាំ១៩៩១ និង១៩៩៣ នៅពេលដែលអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា(អ៊ុនតាក់) បានរៀបចំការបោះឆ្នោតជាតិ។ អង្គការមិនមែនរដ្ឋាភិបាលជាតិភាគច្រើន បានចូលរួមយ៉ាងសកម្មនៅក្នុងការផ្តល់សេវាកម្មចាំបាច់ទូទាំងប្រទេស និងមានអង្គការចំនួនតិចតួចណាស់ដែលចូលរួមការតស៊ូមតិដែលផ្តោតសំខាន់ទៅលើបញ្ហាអភិបាលកិច្ច និងដំណើរការបោះឆ្នោត។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលនានា តែងតែរាយការណ៍ថា មានការជ្រៀតជ្រែកពីអាជ្ញាធរខេត្ត និងមូលដ្ឋាន ។ នេះគឺជាបញ្ហាមួយយ៉ាងពិសេសសម្រាប់អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដែលអនុវត្តកម្មវិធីទាក់ទិននឹងសិទ្ធិមនុស្ស អំពើពុករលួយ ការរំលោភយកដីធ្លី បរិស្ថាន និងការជួញដូរមនុស្ស។

អង្គការមិនមែនរដ្ឋាភិបាលដូចជា គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL) គណៈកម្មាធិការអព្យាក្រិត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា (NICFEC) បានចូលរួមយ៉ាងសកម្មនៅក្នុងការឃ្លាំមើលការបោះឆ្នោតជាតិ និងក្រុមប្រឹក្សាឃុំ-សង្កាត់ ហើយនិងដឹកនាំកម្មវិធីអប់រំអ្នកបោះឆ្នោត។ ពួកគេបានបំពេញតួនាទីយ៉ាងសំខាន់នៅក្នុងការឃ្លាំមើលដំណាក់កាលនីមួយៗនៃដំណើរការបោះឆ្នោត ដោយរួមទាំងដំណាក់កាលចុះឈ្មោះបោះឆ្នោត និងរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោត ដំណើរការចុះបញ្ជីគណបក្សនយោបាយ អំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ថ្ងៃបោះឆ្នោត និងការរាប់សន្លឹកឆ្នោតព្រមទាំងដំណើរការដោះស្រាយបណ្តឹង។ ការត្រួតពិនិត្យលើដំណាក់កាលនីមួយៗនៃដំណើរការនេះ មានសារៈសំខាន់ណាស់ ពីព្រោះមានការចោទប្រកាន់ពីការប្រព្រឹត្តមិនត្រឹមត្រូវជាច្រើនដែលកើតឡើងកន្លងមកដែលពាក់ព័ន្ធទៅនឹងសកម្មភាពទាំងឡាយដែលកើតមាននៅមុន និងក្រោយថ្ងៃបោះឆ្នោត។

អង្គការមិនមែនរដ្ឋាភិបាលនានា បន្តរៀបចំកិច្ចពិភាក្សា ប្រកបដោយជោគជ័យក្នុងចំណោមអ្នកដែលពាក់ព័ន្ធនឹងការបោះឆ្នោត។ អង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត បានធ្វើការយ៉ាងសកម្មនៅក្នុងការលើកកម្ពស់

ការចូលរួមរបស់ស្ត្រីនៅក្នុងការបោះឆ្នោតតាមរយៈសកម្មភាពនានាដូចជាវេទិកាសាធារណៈ និងការបណ្តុះបណ្តាលបេក្ខជន។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានផលិត និងចែកសម្ភារៈសម្រាប់អប់រំអ្នកបោះឆ្នោតទៅដល់ប្រជាពលរដ្ឋដូចជាមគ្គុទេសក៍សម្រាប់អ្នកបោះឆ្នោតជាដើម។

## អនុសាសន៍

ថ្វីត្បិតតែមានកំហុសធំៗកើតឡើង នៅក្នុងដំណើរការបោះឆ្នោតរបស់កម្ពុជាក៏ដោយ ក៏មានវិធានការជាច្រើនអាចប្រើប្រាស់ដើម្បីធ្វើឱ្យការបោះឆ្នោតនាពេលខាងមុខនេះប្រសើរឡើងបានផងដែរ។ ហេតុដូចនេះហើយ ដោយឈរលើស្មារតីសហប្រតិបត្តិការអន្តរជាតិ គណៈប្រតិភូសូមផ្តល់ជាអនុសាសន៍មួយចំនួនដូចខាងក្រោមៈ

### គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ( គ.ជ.ប)

គ.ជ.ប គួរតែចាត់វិធានការរដ្ឋបាលឱ្យខ្លាំងក្លាទៅនឹងការរំលោភលើច្បាប់បោះឆ្នោត និងបទបញ្ជាផ្សេងៗទាំងនេះរួមមាន ការដាក់ទណ្ឌកម្មទៅលើមន្ត្រីបោះឆ្នោតណាមួយដែលមិនបានអនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានពេញលេញ។ ជម្លោះទាក់ទងនឹងការបោះឆ្នោតទាំងឡាយ ត្រូវតែដោះស្រាយក្នុងលក្ខណៈត្រឹមត្រូវ និង តម្លាភាព។

គ.ជ.ប គួរតែពិនិត្យឡើងវិញលើដំណើរការដោះស្រាយបណ្តឹង ដើម្បីធានាថា អ្នកដែលចូលរួមក្នុងដំណើរការបណ្តឹងនេះពិតជាអាចយល់យ៉ាងច្បាស់ និងគួរឱ្យជឿជាក់។

គ.ជ.ប គួរតែទាមទារនូវអំណាចច្បាប់របស់ខ្លួនដែលមានចែងក្នុងមាត្រា៧៥នៃច្បាប់ ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដើម្បីធានាថាគណបក្សនយោបាយដែលបានចុះបញ្ជីរួច ទទួលបានការផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយស្មើភាពគ្នានៅក្នុងអំឡុងពេលធ្វើយុទ្ធនាការឃោសនាបោះឆ្នោត។

គ.ជ.ប គួរតែប្រើប្រាស់ការប្រជុំដែលបានកំណត់យ៉ាងទៀងទាត់ ជាមួយនឹងគណបក្សនយោបាយនានាជាមធ្យោបាយសម្រាប់ដោះស្រាយទំនាស់ ក៏ដូចជាសម្រាប់ផ្សព្វផ្សាយព័ត៌មាន។

ប្រសិនបើបញ្ហាទាក់ទងនឹងឈ្មោះអ្នកបោះឆ្នោតដែលគ.ជ.បបានលុបចេញ មិនត្រូវបានដោះស្រាយប្រកបដោយការពេញចិត្តនោះទេ បញ្ជីលុបឈ្មោះអ្នកបោះឆ្នោតនោះ ត្រូវទុកជាបញ្ជីឈ្មោះអ្នកបោះឆ្នោតបន្ថែមនៅក្នុងថ្ងៃបោះឆ្នោត។

### លទ្ធភាពទទួលបានការផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ

រដ្ឋាភិបាល គួរតែបង្កើតឱ្យមានដំណើរការប្រកបដោយភាពត្រឹមត្រូវ និងមានតម្លាភាពសម្រាប់ការផ្តល់អាជ្ញាប័ណ្ណផ្សព្វផ្សាយ ពោលគឺមិនមានអាជ្ញាប័ណ្ណណាមួយ គួរតែត្រូវបានផ្តល់ជូន និងបដិសេធដោយផ្អែកទៅលើនិន្នាការនយោបាយរបស់អ្នកស្នើសុំនោះទេ។ រដ្ឋាភិបាល គួរតែធានាថារាល់ទស្សនៈនយោបាយទាំងឡាយត្រូវបានបង្ហាញឱ្យបានត្រឹមត្រូវនៅតាមទូរទស្សន៍របស់រដ្ឋ។ គ.ជ.ប និងក្រសួងមហាផ្ទៃ គួរតែធានាថាកិច្ចពិភាក្សាបេក្ខជនរវាងគណបក្សដែលប្រកួតប្រជែងគ្នាដែលកំពុងតែគ្រោងនឹងរៀបចំ នឹងទទួលបានការគ្របដណ្តប់ដោយប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ។ អ្នកដឹកនាំគណបក្សកាន់អំណាច និងគណបក្សប្រឆាំង គួរតែពិភាក្សាដេញដោលគ្នា

នៅតាមកញ្ចក់ទូរទស្សន៍ និងវិទ្យុដើម្បីជួយធានាថាអ្នកបោះឆ្នោត អាចធ្វើការសម្រេចជ្រើសរើសតំណាងរបស់ពួកគេឱ្យបានត្រឹមត្រូវ ។

**រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**

គ.ជ.ប គួរតែត្រូវបានអនុញ្ញាត ដើម្បីស្នើសុំថវិការបស់ខ្លួនដោយផ្ទាល់ទៅកាន់រដ្ឋសភាជាជាងទៅ កាន់ក្រសួងមហាផ្ទៃ។ កិច្ចខិតខំប្រឹងប្រែងទាំងឡាយ ត្រូវតែធ្វើឡើងដើម្បីផ្តល់ថវិកាដើម្បីផ្លាស់ប្តូរទីតាំងការិយាល័យរបស់គ.ជ.ប ។ ការធ្វើបែបនេះ នឹងកាត់បន្ថយការចោទប្រកាន់អំពីភាពលំអៀង និងកង្វះឯករាជ្យភាពរបស់ គ.ជ.ប ។

បុគ្គលណាមួយដែលបានប្រើប្រាស់ធនធានរបស់រដ្ឋខុសដើម្បីគាំទ្រ និងប្រឆាំងនឹងបេក្ខជនណាមួយគួរតែត្រូវបានដាក់ទោសទៅតាមច្បាប់ជាធរមាន ។

វាគឺជាការសំខាន់ និងចាំបាច់ដែលត្រូវតែចាប់ខ្លួន និងដាក់ទោសភ្លាម១ចំពោះបុគ្គលណាមួយ ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើហឹង្សា និងការបំភិតបំភ័យសមាជិកគណបក្សនយោបាយ និងសមាជិកអង្គការសង្គមស៊ីវិល។ រដ្ឋាភិបាល គួរតែកុំប្រើប្រាស់ច្បាប់បរិហារកេរ្តិ៍ព្រហ្មទណ្ឌ និងរដ្ឋប្បវេណីប្រឆាំងនឹងគូប្រជែងនយោបាយពីព្រោះទង្វើអស់ទាំងនេះ នឹងបំភិតបំភ័យ គម្រាមកំហែងដល់គណបក្សប្រឆាំង និងបង្ក្រាបអ្នកប្រជាធិបតេយ្យ ។

មាត្រា៣៧នៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់សិទ្ធិក្នុងការធ្វើកូដកម្ម និងបាតុកម្មអហឹង្សា ហើយមាត្រា៤១ បានការពារសិទ្ធិសេរីភាពខាងការប្រជុំ។ ដូចនេះរដ្ឋាភិបាល គួរតែគោរពសិទ្ធិសេរីភាពទាំងនេះ។ សេរីភាពខាងការប្រជុំ ក៏ត្រូវបានធានាក្រោមកិច្ចព្រមព្រៀងអន្តរជាតិផងដែរ ដូចជាកិតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (International Covenant on Civil and Political Rights) ជាដើម ។

**សហគមន៍អន្តរជាតិ**

ពួកយើងជម្រុញឱ្យសហគមន៍អន្តរជាតិ បន្តការឧបត្ថម្ភគាំទ្រអង្គការឃ្លាំមើលការបោះឆ្នោត និងអង្គការមិនមែនរដ្ឋាភិបាល(NGOs)នានាដែលចូលរួមក្នុងដំណើរការបោះឆ្នោតដើម្បីធានាថា ពួកគេមានធនធានគ្រប់គ្រាន់ដើម្បីអនុវត្តសកម្មភាពការងាររបស់ពួកគេ ។